**BMI0190**

# សម្ភាសន៍ជាមួយឈ្មោះ លត ណុ ភេទប្រុស អាយុ៨៥ឆ្នាំ

## មុខងារនៅសម័យខ្មែរក្រហមៈ "ខាងសង្គមកិច្ច"

## សព្វថ្ងៃរស់នៅភូមិជើងវត្ត ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១

## សម្ភាសន៍ដោយៈ សោម ប៊ុនថន

## ០០:២៨:២១

## ៩ទំព័រ

ប៊ុនថន : អ៊ំឈ្មោះអីវិញ?

ណុ : ខ្ញុំឈ្មោះ នាមត្រកូល លត ណុ ។

ប៊ុនថន : លត អីវិញអ៊ំ?

ណុ : លត ណុ ។

ប៊ុនថន : បាទ! សព្វថ្ងៃអាយុ៨៥ឆ្នាំអ៊ំ?

ណុ : ៨៥ ។

ប៊ុនថន : ស្រុកកំណើត ភូមិនៅភូមិជើងវត្ត ភូមិព្រះនេត្រព្រះ?

ណុ : ព្រះនេត្រព្រះ ។

ប៊ុនថន : កាលណោះអ៊ំបងប្អូនប៉ុន្មាននាក់អ៊ំ?

ណុ : ខ្ញុំបងប្អូន...មួយ ពីរ បី បួន ប្រាំ ។

ប៊ុនថន : បងប្អូន៥នាក់ ។ សព្វថ្ងៃនៅរស់ទាំងអស់ទេ?

ណុ : ស្លាប់ខ្លះអស់ហើយ នៅរស់តែខ្ញុំ បី បួននាក់ ។

ប៊ុនថន : ចុះអ៊ំមានបានរៀនអីទេ? រៀនសូត្រអីពីដើមណា?

ណុ : រៀនសូត្រ ។

ប៊ុនថន : បាទ! រៀនសូត្រនៅសាលាណា?

ណុ : បាទ! ខ្ញុំដូច...នៅ..

ប៊ុនថន : នៅវត្តតាំងពីក្មេងមក នៅវត្តណាវិញ?

ណុ : វត្តព្រះនេត្រព្រះ ។

ប៊ុនថន : វត្តព្រះនេត្រព្រះវិញ ។ វត្តហ្នឹងកើតឆ្នាំប៉ុន្មាន អ៊ំមានដឹងទេ?

Documentation Center of Cambodia
Searching for the Truth: Memory & Justice ស្វែងរកការពិត ដើម្បីការចងចាំ និងយុត្តិធម៌
66 Preah Sihanouk Blvd. • P.O.Box 1110 • Phnom Penh • Cambodia
t (855-23) 211-875 • f (855-23) 210-358 • dccam@online.com.kh • www.dccam.org

ណុ : មិនដឹងតាំងពីសករាជប៉ុន្មានទេ កើតមកឃើញតែវត្ត ព្រះពុទ្ធរូប... កើតមកឃើញតែវត្ត ។

ប៊ុនថន : បាទ! ពីក្មេងមក ។

ណុ : មានរៀនសាលា កាលណោះមិនទាន់មាន.. រៀនបារាំង... ទៅមក ក-ខ តែប៉ុណ្ណឹងឯង ។ ការរៀន រៀនបានមួយឆ្នាំក៏រៀន សាលាហ្នឹងសាលានៅវត្ត ។

ប៊ុនថន : ហើយកាលហ្នឹងមានវិហារមានអីនៅទេ?

ណុ : វិហារសព្វគ្រប់ហ្នឹង ។

ប៊ុនថន : មានលោកមានអីដែរ?

ណុ : លោក ។

ប៊ុនថន : កាលហ្នឹងសង្ឃរាជ កាលជំនាន់អ៊ឹ ឈ្មោះអីវិញ?

ណុ : ឈ្មោះ តេកគុណ ម៉ុច ។

ប៊ុនថន : តេកគុណ ម៉ុច ។ នាមត្រកូន?

ណុ : នាមត្រកូលលោកស្អី ត្រកូលលោក ។

ប៊ុនថន : ចុះមានលោកនៅក្នុងវត្តហ្នឹងច្រើនអង្គអត់?

ណុ : កាលខ្ញុំនៅដូចច្រើនដែរ ៥០-៦០អង្គ ។

ប៊ុនថន : អូ! ច្រើនដែរ ។ ចុះអ្នកភូមិអីមានច្រើនគ្រួសារដែរ ឬក៏អត់សូវមានផ្ទះទេ?

ណុ : រាប់ពាន់គ្រួសារ... ។

ប៊ុនថន : ចុះអ៊ំរៀននៅវត្តហ្នឹងរហូតអ៊ំ?

ណុ : ហ្នឹងរហូត ។

ប៊ុនថន : រហូតដល់សម័យលន់ នល់?

ណុ : មើលសាស្ត្រា ស្លឹករឹតហ្នឹងណា ។ យើងរៀនវត្តហ្នឹងចប់ យើងមើលសាស្ត្រា ស្លឹករឹតហ្នឹងទៅ ។

ប៊ុនថន : ដល់សម័យលន់ នល់ហ្នឹង អ៊ំនៅវត្តហ្នឹងនៅឡើយទេ?

ណុ : ទេ សម័យលន់ នល់ហ្នឹង ខ្ញុំបានគ្រួសារហើយ ។

ប៊ុនថន : គ្រួសារអ៊ីអ្នកនៅក្នុងភូមិហ្នឹងជាមួយគ្នាដែរ?

ណុ : ជុំគ្នា ។

ប៊ុនថន : បានគ្រួសារហើយមកនៅផ្ទះវិញ ឬក៏បែកផ្ទះ?

ណុ : ... ផ្ទះចាស់កំណើត នេះប្អូនខ្ញុំ អានេះផ្ទះខ្មោចបងខ្ញុំ អានេះផ្ទះក្មួយ អានេះផ្ទះប្អូន... ។

ប៊ុនថន ៖ នៅតែម៉្ដុំហ្នឹង ។ ការហើយអ៊ីប្រកបរបរអ្វីដែរ?

ណុ ៖ គ្មានធ្វើអីទេ ធ្វើតែស្រែហ្នឹង ។ គ្មានធ្វើអីទេ សូម្បីតែទាហានក៏មិនធ្វើដែរ ។ កាលមុនគ្មានធ្វើអីទេ ។

ប៊ុនថន ៖ ចុះជំនាន់រំដោះខ្មែរក្រហម រំដោះឆ្នាំ៧៥?

ណុ ៖ គ្មានធ្វើអីទេ រត់តែទ័ពរហូត... ។

ប៊ុនថន ៖ គេជម្លៀសចេញទេ?

ណុ ៖ គេជម្លៀសចេញទៅ ។

ប៊ុនថន ៖ នៅ តាប៉ែន ហ្នឹងអី?

ណុ ៖ តាប៉ែន ។

ប៊ុនថន ៖ ហើយថាអ៊ីបានធ្វើ ។

ណុ ៖ គេឲ្យធ្វើសន្ធមកិច្ច ។

ប៊ុនថន ៖ បាទ! ខាងសន្ធមកិច្ច ។

ណុ ៖ ហើយមើលទៅ៧៦...ហើយធ្វើស្អី ។

ប៊ុនថន ៖ ហើយសន្ធមកិច្ចហ្នឹងតែមួយភូមិទេ នៅតែមួយភូមិតាប៉ែនហ្នឹងទេ មានប៉ុន្មានភូមិ?

ណុ ៖ ត្រពាំងកក់ ប៉ោយព្រីង ។

ប៊ុនថន ៖ ត្រពាំងកក់ ប៉ោយព្រីង ។

ណុ ៖ ហើយធ្វើដើម្បីអីទេ...អាណិតគ្នាឯង ។ មកវិញបបរទឹករាវកក្អកដូចតែគ្នា ។ អាឯងនេះទៅអីចេះទៅបបរ មិនធ្វើទៅ បញ្ជោរគេ ខ្លាចសម្លាប់ចោល គេប្រើរាល់ថ្ងៃ មិនដឹងធ្វើម៉េច ។ រាល់ថ្ងៃព្រុឈ្មោះតែខ្មែរក្រហម អាពតហ្នឹងឯងបាក់ស្បាត ។

ប៊ុនថន ៖ អ៊ីចឹងដល់ពេលខុះខាតអីចឹង អ៊ីអត់រាយការណ៍ទៅលើដូចថាប្រាប់ថាខុះខាត?

ណុ ៖ ខ្ញុំមិនបានរាយការណ៍អីទេ គឺថាដោះស្រាយអីផ្សេងទៅ ដោះស្រាយផ្សេងទៅ ។

ប៊ុនថន ៖ ពីណាអ្នកដោះស្រាយអ៊ី?

ណុ ៖ គេប្រធានលើ កម្មាភិបាល មើលទៅ ។

ប៊ុនថន ៖ កាលហ្នឹងពីណាវិញអ៊ី មានចាំឈ្មោះទេ?

ណុ ៖ មិនស្គាល់ទេ មិនដឹងពីណាទេ ។

ប៊ុនថន ៖ ហើយនៅរស់ទេអ៊ី?

ណុ ៖ អេ! ខ្ញុំអត់ដឹងទេ ។

ប៊ុនថន : អីចឹងមានអ្នកដោះស្រាយពីលើទៀត?

ណុ : គេមានគេហ្នឹងហើយ មួយភូមិហ្នឹងមានតែគេមួយដោះស្រាយ...។

ប៊ុនថន : អីចឹងអីខាងថ្នាំសង្កូវ?

ណុ : ហ្នឹងឯង ថ្នាំសង្កូវ គេចេះតែឲ្យថ្នាំផឹក....។

ប៊ុនថន : ឈឺជំងឺអីខ្លះអីភាគច្រើន?

ណុ : អូយ! និយាយពីជំងឺស្អីខ្លះមិនត្រូវទេ អាខ្លះក៏រាគអាចម៍ទៅ អាខ្លះក៏គ្រុន អូយ! សព្វគ្រប់។

ប៊ុនថន : បាទ! គ្រប់មុខ។

ណុ : បើយកថ្នាំអាធំគេណា អាថ្នាំជំងឺអត់បាយណា...។

ប៊ុនថន : ហើយដូចថានៅហ្នឹងភាគច្រើនមកថ្មីទេអី អ្នកថ្មីអី?

ណុ : អ្នកថ្មីជាមួយអ្នកចាស់មកជាមួយគ្នា ជុំតែគ្នា។

ប៊ុនថន : អ្នកថ្មីមកប្រហែលជាច្រើនទេអី?

ណុ : ថ្មីរាប់ពាន់ រាប់រយមកជុំគ្នា។

ប៊ុនថន : ភាគច្រើនមកពីណាវិញអ្នកថ្មីហ្នឹង?

ណុ : ...ចាំមិនបានមិនដឹងមកពីណាទេ ខាងតាកែវក៏មក ខាងអរិយក្សត្រក៏មក ខាងអ្នកភ្នំពេញក៏មក រួចចាក់អង្រែក្រោមលើក៏មកទៅ វាច្រើន មិនដឹងខាងណាច្រើនលើសខាងណាទេ។ ទ័ពដូចថាព្រឹកៗ គេឲ្យយើងដើរទៅអើតទៅមើលគេ មុខការយើងគេឲ្យទៅស្ទូងដង ស្ទូងដក មុខការយើងគេឲ្យធ្វើអី យើងធ្វើនោះ គេចាត់ចែងគេ ប្រឡូកប្រឡំគេទៅ ប៉ុណ្ណឹងឯង។ មិនបានទេ ខ្ញុំនេះបន់ដីជូនបន់ដីតាឲ្យតែជុតរបបនេះ រស់តែប៉ុណ្ណេះ ខ្ញុំលែងគិតអីហើយ អត់.. ឲ្យតែបានរស់។ អាយុ៨៥ហើយ។

ប៊ុនថន : ចុះមានអ្នកឈឺអីច្រើនទេ?

ណុ : ពីដើមឈឺនេះឈឺ មួយយប់ៗឈឺ អានេះក៏នេះ អានោះក៏ឈឺនេះ...។

ប៊ុនថន : ដល់ពេលឈឺខ្លាំងទៅធ្វើម៉េចទៅ?

ណុ : ឈឺខ្លាំងទៅមិនដឹងធ្វើម៉េច ឈឺខ្លាំងដាក់ថ្នាំទៅ បើត្រូវយើងដាក់ថ្នាំពីឈឺទៅជា បើជាទៅ វានៅមួយឡែកទៀត តែជាវាទាមទារម្ហូបអាហារបាយហើយ យើងត្រូវតែដោះស្រាយរកឲ្យបានឲ្យគ្នា មានអ្នកណាទេ។ ឯងខំទៅសុំឲ្យអានេះ គេថាឯងបក្សសម្ព័ន្ធនឹងគេ យូរទៅគេដេញចោល ស៊ីតែរបបហ្នឹង។

ប៊ុនថន : របបហ្នឹង របប...?

ណុ : គ្នាបីប្អូនរយនាក់ហ្នឹងអត្តរបីកំប៉ុងតើស គ្មានលើសគ្មានខ្វះទេ បើថ្ងៃណាថ្នាក់លើគេដូចថា គេឲ្យមក បីប្អូននាក់ហ្នឹងបានប្រាំកំប៉ុង ។

ប៊ុនថន : បាទ! បីប្អូននាក់បានប្រាំកំប៉ុង ។

ណុ : ប្រាំកំប៉ុងហ្នឹងបបរដាក់ជាមួយគ្នាបីប្អូននាក់ ។ ថ្ងៃឡើងទៅធ្វើការឲ្យគេទៅ ទៅបេះស្លឹកឈើ ស្លឹកព្រៃ គ្មានធ្វើការ ធ្វើការតែហ្នឹងឯង ។

ប៊ុនថន : អីចឹងមានអ្នកឈឺស្លាប់ទេ ដូចថាដាដាក់ថ្នាំ?

ណុ : អូ! មានច្រើនណាស់ ងាប់មិនមែនតិចទេ មិនមែនងាប់ដោយជំងឺនឹងឈឺទេ ងាប់ដោយ អត់បាយ ងាប់ដោយអត់បាយមានច្រើនណាស់ គ្រាន់តែប្អូនខ្ញុំពីរ កូនអ្នកអរីក្សត្រ.... អាណាទៅចាំខ្មោចនោះបាន ប៉ុន្តែងាប់ហ្នឹងបង្សុកូល បាំងអីឲ្យ ។

ប៊ុនថន : ភាគច្រើនអ្នកថ្មីអីអ៊ី?

ណុ : យី! .... ដូចថាងាប់ទាំងចាស់ ទាំងថ្មី ចុះរបបដូចតែគ្នា ចុះមានអាចាស់របបប៉ុណ្ណេះ អាថ្មី របបប៉ុណ្ណោះឯណា.... ។

ប៊ុនថន : ចុះចាស់ៗនៅជាមួយអ៊ំប៉ុន្មាននាក់ មានចាំឈ្មោះទេ?

ណុ : នៅម៉េច?

ប៊ុនថន : នៅអ៊ំជួយឲ្យ ជួយចិញ្ចឹមផ្គត់ផ្គង់ណា?

ណុ : អេ! ខ្ញុំមិនដែលបានជួយចិញ្ចឹមផ្គត់ផ្គង់គេ មិនដែលប៉ះពាល់អីទេ ដើរតែមើលទេ គេឲ្យរក ថ្នាំអីនេះ ឲ្យធ្វើយ៉ាងម៉េច ។

ប៊ុនថន : ចុះថាអ្នកនៅតាកែវស្គាល់អ៊ំហ្នឹង?

ណុ : អាហ្នឹងកូនយាយខ្ញុំទេ.... ។

ប៊ុនថន : ចុះអ្នកនៅភ្នំពេញ ម្ដុំចាក់អង្រែ?

ណុ : នៅភ្នំពេញឈ្មោះ អាអឿន ឈ្មោះ អាយ៉ាវ ។

ប៊ុនថន : ជំនាន់ហ្នឹងជម្លៀសមក?

ណុ : មកនៅជាមួយខ្ញុំ ។ បើនិយាយទៅថាខ្ញុំ....មិនដែលឲ្យបងប្អូនមានទុក្ខ.... បើទោះបីជាយ៉ាង ណាក៏ដោយ អ្នកឯងធ្វើម៉េចធ្វើទៅ ក្បាលអ្នកណា សក់អ្នកហ្នឹង ។ មិនដែលទេ កើត មួយជាតិ នេះមានពៀរ មានវេរា មានបងប្អូនមកពីជិតឆ្ងាយ ។ ឃើញមកពីឆ្ងាយមក

សើចដាក់ខ្ញុំអីចេះ ខ្ញុំថា.... ខ្ញុំនិយាយអាណាដែលត្រង់....គ្រាន់តែថាយកឲ្យទៅ.....
ដើតគេបតគុប តគេបតគះឃើញ ណា! ឃើញមុខសើច ។

ប៊ុនថន : ហើយអ្នកដែលជម្លៀសមកហ្នឹងសុទ្ធតែមក?

ណុ : ពួកមកពីអរិយក្សត្រ ។

ប៊ុនថន : បាទ! មកពីភ្នំពេញហ្នឹងមកជួបអីនៅនេះ?

ណុ : នៅនេះ ។

ប៊ុនថន : ហើយបានស្គាល់គ្នាតាំងពីហ្នឹងមក ។

ណុ : មកដាំបាយដាំទឹក ហើយម្ហូបប៉ុន្មាន...។ គេមកបង្សុកូលខ្មោច ហែខ្មោចឪ ជីដូនជីតា.... ក៏ជូនទៅ ប៉ុន្តែរកកន្លែងមិនឃើញទេ អញវង្វេងហើយ ។ ហើយសព្វថ្ងៃនេះគេ.... ។

ប៊ុនថន : គេខស្សាហ៍មកដែរទេអីអឺ មកបុណ្យបង្សុកូល ។

ណុ : ...មក... ។

ប៊ុនថន : អឺដូចវត្តនេះសម័យហ្នឹងគេធ្វើអីវិញអឺ ព្រះនេត្រព្រះយើង?

ណុ : អូ! វ៉ៃគ្នាបំបាក់-ក រុះសាលាអី..... ។

ប៊ុនថន : អូ! មន្ទីរពេទ្យហ្នឹង ហៅមន្ទីរពេទ្យអីវិញ?

ណុ : មន្ទីរពេទ្យអាក្រហម អាខ្មៅហ្នឹង ដូចថាធ្វើដូចយើង...ឲ្យតែងាប់ហ្នឹង ។

ប៊ុនថន : មន្ទីរពេទ្យភូមិឃុំ ឬក៏ស្រុក?

ណុ : មកត្រង់នេះ... ។

ប៊ុនថន : នេះមន្ទីរពេទ្យព្រះនេត្រព្រះ?

ណុ : ហ្នឹងឯង ។ មានស្អី... ។

ប៊ុនថន : ចុះលោកអីចេញសឹកអស់ហើយ?

ណុ : សឹកតាំងពីចូលមក ។ ចូលមក៧៥...មិនដឹងជាធ្វើម៉េច... កសាងសាលា កសាងវត្ត ណា... ។

ប៊ុនថន : បាទ!

ណុ : និយាយរឿងនេះកំសត់ណាស់ ។

ប៊ុនថន : ចុះអឺនៅហ្នឹងដូចថាថ្វាយបង្គំព្រះអីគេអត់រករឿងអីទេ?

ណុ ៖ ថ្វាយបង្គំព្រះ ខ្ញុំមកពិធី...ថ្វាយបង្គំព្រះ បានសូត្រធម៌ ស្លៀកសង្ឃហើយ គេៗទៅ ។ អុជធូបថាមូសវាខាំ កុហកគេទេ ។ មែនទែនសូទ្រធម៌ ខ្ញុំមិនចេះធម៌ មិនចេះអារ្យអីទេ ។ កុហកគេ ។

ប៊ុនថន ៖ ខាងណាគេមកឃើញអ៊ឹ?

ណុ ៖ កម្មាភិបាលស្រុកឆ្លូង... ។

ប៊ុនថន ៖ ដោយសារអ៊ី និយាយថានៅវត្តហ្នឹងចេះធម៌អារ្យខ្លះដែរអ៊ី?

ណុ ៖ ចេះទៅអួតគេ... ទំរាំតែព្រះគេវាយព្រះ គេហ៊ានវាយបំបាក់-ក ចុះទៅជឿអីបុគ្គល ។ សព្វថ្ងៃនេះគេ...សង្គមនេះអាក្រក់ សង្គមនេះល្អ ខ្ញុំមិនហ៊ាននិយាយទេ មើលតែមុខគេឡិឡក់ៗ ។

ប៊ុនថន ៖ ចុះឆ្នាំប៉ុន្មានមាននេះវិញ មានវត្ត?

ណុ ៖ បាទ!

ប៊ុនថន ៖ ចុះឆ្នាំប៉ុន្មានមានវត្ត មានលោកណា បែកហើយ៧៩ហើយ?

ណុ ៖ ៧៩ហើយ ។

ប៊ុនថន ៖ ឆ្នាំប៉ុន្មានបានមានលោកមានអីមកនៅវិញ?

ណុ ៖ ...ដូចមានតែលោក៥អង្គ... ចេញពីនោះមកដូចអត់មានលោកទេ...ដែលថារាងចាស់ពីដើមមកណា... ។

ប៊ុនថន ៖ ចុះអ្នកណានៅដំបូងគេអ៊ឹ សង្ឃរាជណា?

ណុ ៖ ដំបូងមក តាអៀន លោក តាអៀន លោកតាសែ លោកតាដុន លោកតាអី ។ ក្រោយមកទើបមានពីរអង្គ...សល់តែគាត់មួយ កុដិថ្មមួយ.. សល់តែវិហារ... នៅសល់តែក្បាលខ្លួនបាត់ ។ គ្រាន់តែនិយាយប្រាប់ ក្មេចមុខ ក្មេចក្រោយ ។ វាជាកសិណ វាជាសាក្សី ។ ហើយពីដើមមក... ។

ប៊ុនថន ៖ ចុះអ៊ីឥឡូវខស្សប្រាហ៍ទៅវត្តដែរអ៊ី?

ណុ ៖ ទេ! ខ្ញុំមិនដែលខានទេ ។

ប៊ុនថន ៖ ទៅរាល់ៗសីល?

ណុ ៖ ទៅរាល់ៗសីល មិនដែលដាច់ទេ ។ ចេញចូលៗវត្តសព្វថ្ងៃ...មិនដែលដាច់ទេ ។

ប៊ុនថន ៖ ហើយកូនប៉ុន្មាននាក់សព្វថ្ងៃ?

ណុ ៖ កូនបួននាក់ ។ ប្រុសពីរ ស្រីពីរ ។ កូនកំណើត ប្រុសពីរ ស្រីពីរ ។ កូនសម័យក្រោយ... ។

ប៊ុនថន ៖ ចុះអ៊ីដែលពុកគេកាត់ទោសខ្មែរក្រហមទេ? កាត់ទោសមេខ្មែរក្រហមណា?

ណុ ៖ ពុ ពុថាគេកាត់ទោស....។

ប៊ុនថន ៖ ចុះអ៊ីយល់ថាម៉េចដែរ?

ណុ ៖ តាម៉ុក ខៀវ សំផន តាំងពីស្អីមួយទៀតទេ។

ប៊ុនថន ៖ ចុះអ៊ីយល់ម៉េចដែរគាត់កាត់ទោស?

ណុ ៖ ទេ! ខ្ញុំយល់ថាតាម...តាមអំពើកម្ម...មិនមែនផ្តន្ទាថាអ្នកនេះឯងចេះ អ្នកឯងចុះ ខ្ញុំអត់ទេ។

ប៊ុនថន ៖ ប៉ុន្តែដូចធម៌ព្រះមានអត់ឱនអីចឹងដែរ កុំឲ្យយកពៀរចងពៀរអីចឹងណា?

ណុ ៖ ទេ! អាហ្នឹងដោយឡែកវាផ្សេងទេ ថា...កុសល្យមានកុសល្យ អកុសល្យមកពីកត្តា... អាហ្នឹងវាមានដោយឡែក អាមួយវាព្រះពុទ្ធសាសនា អាហ្នឹងច្បាប់វាកាត់តែមួយ ដូចយើងសម័យ... បងតូចបងធំ សម្អាងលើផលសាងជាកម្ម ក៏កម្មទៅ...ធ្វើចេះបាប ធ្វើចេះបុណ្យ បើអ្នកកាន់មិនគោរពតាមដំណើរទៅ យើងគោរពរៀងខ្លួន ដូចសព្វថ្ងៃ ដូច យើងគោរពច្បាប់សព្វថ្ងៃ ច្បាប់គេដាស់តឿសអីចឹង យើងកាន់ច្បាប់ទៅ ដូចលោកដាក់ សិក្ខាបទអីចឹង យើងកាន់កាប់ច្បាប់កាន់ពិន័យ តាជ៉ាណាន់ កុំសម្លាប់សត្វ អាទានាព្រី យើងកុំប៉ះពាល់ កម្មមាប្រពន្ធគេកូនគេ..។ ដល់ពាក្យរដ្ឋាភិបាល បើខុសធ្វើទារុណកម្មទៅ សារគេប្រាប់មុនតើស សិក្ខាបទប្រាប់យើងឲ្យយើងដឹង បើថាឯងចេះតែបំពាន ដូចថាព្រះ ថាផលកម្មនៃខ្លួន ទទួលកម្មទៅ។ មិនដឹងនិយាយម៉េច ខ្ញុំចេះតែនិយាយទៅ ខ្ញុំនិយាយចេះ តែភ្លេចភ្លាំង និយាយរួចហើយថាមិនទាន់បាននិយាយ ។

ប៊ុនថន ៖ កាលហ្នឹងសង្គមកិច្ចថ្នាំ មានថ្នាំពេទ្យមានអីទេ?

ណុ ៖ មាន ។

ប៊ុនថន ៖ គេថាមានថ្នាំពេទ្យមានអី?

ណុ ៖ ហ៊ឺ! ថ្នាំពេទ្យតែគ្នាវាហ្នឹង ឯងមិនទាន់បានរំពុកអាថ្នាំពេទ្យប៉ាវ៉ា...។

ប៊ុនថន ៖ អីចឹងអ៊ីអ្នកដើររកឫសឈើអីមកផ្សំ?

ណុ ៖ រកឫស្សីអីផ្សំ...។

ប៊ុនថន ៖ ចុះអ៊ីចេះដូចថារូបមន្តហ្នឹងមកពីណាវិញអ៊ី?

ណុ ៖ ចេះរូបមន្តហ្នឹងនិយាយតាមប្រវត្តិចេះតាមជីដូនជីតាមក ចេះពីមុនមក។

ប៊ុនថន ៖ អីចឹងចេះពីមុនមកឲ្យអ៊ីកាន់ថ្នាំ ។

ណុ ៖ បាទ!

ប៊ុនថន ៖ និយាយថាចេះតាំងពីមុនមកទៀត អីចឹងគេឲ្យអីកាន់ថ្នាំកាន់អីម៉េង?

ណុ ៖ ចេះតិចៗ...ចុះមានតែតែឫសឈើ ឫសព្រៃ ចាន់ស ចាន់ក្រហម ចាន់គ្រឹះស្នា.. ទៅរកឲ្យបានថ្នាំហ្នឹង ។

ប៊ុនថន ៖ ចុះយើងធ្វើម៉េចបានដឹងដូចថាជំងឺរាកអីដាក់ថ្នាំម៉េច ឈើគ្រុនក្តៅអីដាក់ម៉េចៗ ?

ណុ ៖ គ្រុនក្តៅប្រើ...សព្វថ្ងៃនេះបានថា ខ្ញុំមិនហ៊ាននិយាយទេ ព្រោះពេទ្យមួយសកលលោកគេប្រើអស់ហើយ បើថានរណាគេរកទៅ...មាន...ចាន់ស ចាន់ក្រហមដុសដឹកទៅ ។ បើវារាករកទៅ សម្បកឈើ សម្បកស្វាយ...។

ប៊ុនថន ៖ ជាដែរ ដាក់ទៅជាទេ?

ណុ ៖ ជាខ្លះ ងាប់ខ្លះ ។

ប៊ុនថន ៖ ហើយអីស្លាប់ទៅដូចថាមានបង្សុកូលអីឲ្យ គេអត់ថាអីដែរអ៊ំ គេអត់ហាមឃាត់ទេ?

ណុ ៖ អាពតហ្នឹង?

ប៊ុនថន ៖ បាទ!

ណុ ៖ មានលោកឯណាបង្សុកូល ។

ប៊ុនថន ៖ ក្រោយមកបានមានទេ?

ណុ ៖ ហ្នឹងហើយ ក្រោយសម្តេចហ៊ុន សែន លោកបង្កើតបានមានលោកសង្ឃលោកអី ចេះធម៌បានសូត្រឲ្យពួ ក៏ជឿទៅ ជឿឯង ។

ប៊ុនថន ៖ ចុះស្លាប់?

ណុ ៖ ស្លាប់យកទៅកប់ទៅ បើយើងផ្សឹកយើងអីចេះថា គ្រាន់តែប្រាប់...យើងខ្សឹបប្រាប់គេទៅ មិនដឹងថាគ្នាបានចាំ មិនបានចាំ ។ នេះមិនដឹងនិយាយម៉េចនឹងត្រូវ នេះវាចាស់ ។ ហ៊ឺ! និយាយមិនបានទេរឿងនេះ ក៏មិនស្អប់គេទេ គិតតាមធម៌ព្រះ កុសាលា អាកុសាលា កុសល្យ អកុសល្យ...។ គេហៅច្បាប់សាកលលោករដ្ឋាភិបាល ច្បាប់លោកណា... និយាយ ។

ប៊ុនថន ៖ អីចឹងខ្ញុំអរគុណអ៊ំហើយណា ។

«ចប់»